អេស៊ីលីដា
ACLEDA BANK

# របាយការណ៍ប្រចាំត្រីមាសទី៣

គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២

## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (គិតជាលានរៀល) | ត្រីមាសទី៣ ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ |
|---|---|---|---|
| ទ្រព្យសកម្មសរុប | ៣៤.៥១៧.៧៥៦ | ៣២.០០២.២៩៨ | ២៦.៥០០.៧៩៣ |
| បំណុលសរុប | ២៩.២៩០.៤៩៦ | ២៧.០៩២.៩៨៥ | ២២.០៩៣.២៥៨ |
| មូលធនសរុប | ៥.២២៧.២៦០ | ៤.៩០៩.៣១៣ | ៤.៤០៧.៥៣៥ |
| **លទ្ធផលហិរញ្ញវត្ថុ (គិតជាលានរៀល)** | **ត្រីមាសទី៣ ឆ្នាំ២០២២** | **ត្រីមាសទី៣ ឆ្នាំ២០២១** | **ត្រីមាសទី៣ ឆ្នាំ២០២០** |
| ចំណូលសរុប | ៧៧៦.៥៣៦ | ៦៥៦.៨៩២ | ៥៨៤.២៤៦ |
| ចំណេញ/(ខាត) មុនបង់ពន្ធ | ២៥៤.០២៥ | ១៩៨.៥៣៧ | ១៨០.៦៧១ |
| ចំណេញ/(ខាត) សុទ្ធក្នុងការិយបរិច្ឆេទ | ២០៣.០១៦ | ១៥៨.៦៩៥ | ១៤១.៩៤៦ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | ២៦៨.៧៦១ | ១៤៤.៧១៨ | ១៤៣.៧១៧ |
| **អនុបាតហិរញ្ញវត្ថុ (%)** | **ត្រីមាសទី៣ ឆ្នាំ២០២២** | **ឆ្នាំ២០២១** | **ឆ្នាំ២០២០** |
| អនុបាតសាធនភាព | ១៩,៥៤% | ២២,៣៦% | ២៥,១៥% |
| អនុបាតបំណុលធៀបនឹងមូលធន | ៥៦០,៣៤% | ៥៥១,៨៧% | ៥០១,២៦% |
| អនុបាតក្របខ័ណ្ឌសន្ទនីយភាព | ១៦០,៤៦% | ១៥៥,៦៥% | ១៤៩,៣១% |
| អនុបាតឥណទានមិនដំណើរការ (*) | ២,៨៦% | ២,៣៣% | ២,៤០% |
| អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើ | ១០៥,៨៤% | ៩៤,៩៧% | ៩៧,៧៣% |
| តម្លៃចុះបញ្ជីក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ១២.០១០ | ១១.២៧៧ | ១០.១៧៥ |
| | **ត្រីមាសទី៣ ឆ្នាំ២០២២** | **ត្រីមាសទី៣ ឆ្នាំ២០២១** | **ត្រីមាសទី៣ ឆ្នាំ២០២០** |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម (ROAA)(**) | ០,៥៩% | ០,៥៣% | ០,៥៥% |
| អនុបាតចំណេញធៀបនឹងមូលធនមធ្យម (ROAE)(**) | ៤,០១% | ៣,២៩% | ៣,៣៧% |
| អនុបាតលទ្ធភាពបង់ការប្រាក់ (ដង) | ២,០៩ | ២,០៩ | ២,១៨ |
| ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ៤៦៨,៨៧ | ៣៦៦,៧៤ | ៣២៧,៧០ |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | គ្មាន | គ្មាន | គ្មាន |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត | គ្មាន | គ្មាន | គ្មាន |

(*) ឥណទានមិនដំណើរការ = ឥណទាននៅដំណាក់កាលទី៣

(**) . អនុបាតទាំងនេះមិនមែនជាអនុបាតប្រចាំឆ្នាំនោះទេ ហើយត្រូវបានគណនាដោយប្រើតួលេខប្រាក់ចំណេញដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគាររយៈពេល ៣ខែ ចាប់ពីថ្ងៃទី០១ ខែកក្កដា ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២។

. ចំណេញធៀបនឹងមូលធនមធ្យម = ប្រាក់ចំណេញដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគារ / មូលធនសរុបមធ្យមរបស់ភាគហ៊ុនិករបស់ធនាគារ

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប








អនុបាតហិរញ្ញវត្ថុ (%)
៥៦០,៣៤%
៥៥១,៨៧%
៥០១,២៦%
១៦០,៤៦%
១៥៥,៦៥%
១៤៩,៣១%
២,៨៦%
២,៣៣%
២,៤០%
១០៥,៨៤%
៩៤,៩៧%
៩៧,៧៣%
១៩,៥៤%
២២,៣៦%
២៥,១៥%
អនុបាតសាធនភាព
អនុបាតបំណុលធៀប នឹងមូលធន
អនុបាតក្របខ័ណ្ឌ សន្ទនីយភាព
អនុបាតឥណទាន មិនដំណើរការ
អនុបាតឥណទានធៀប នឹងប្រាក់បញ្ញើ
ត្រីមាសទី៣ ឆ្នាំ២០២២
ឆ្នាំ២០២១
ឆ្នាំ២០២០




៤,០១%
៣,២៩%
៣,៣៧%
០,៥៩%
០,៥៣%
០,៥៥%
អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម (ROAA)
អនុបាតចំណេញធៀបនឹងមូលធនមធ្យម (ROAE)
ត្រីមាសទី៣ ឆ្នាំ២០២២
ត្រីមាសទី៣ ឆ្នាំ២០២១
ត្រីមាសទី៣ ឆ្នាំ២០២០



ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល)
៣២៧,៧០
៣៦៦,៧៤
៤៦៨,៨៧
ត្រីមាសទី៣ ឆ្នាំ២០២០
ត្រីមាសទី៣ ឆ្នាំ២០២១
ត្រីមាសទី៣ ឆ្នាំ២០២២
ត្រីមាសទី៣ ឆ្នាំ២០២០
ត្រីមាសទី៣ ឆ្នាំ២០២១
ត្រីមាសទី៣ ឆ្នាំ២០២២




តម្លៃចុះបញ្ជីក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល)
១០.១៧៥
១១.២៧៧
១២.០១០
ឆ្នាំ២០២០
ឆ្នាំ២០២១
ត្រីមាសទី៣ ឆ្នាំ២០២២
ឆ្នាំ២០២០
ឆ្នាំ២០២១
ត្រីមាសទី៣ ឆ្នាំ២០២២

# សមាសភាពក្រុមប្រឹក្សាភិបាល



**លោក ឆាយ សឿន**
*ប្រធានក្រុមប្រឹក្សាភិបាល*



**បណ្ឌិត អ៊ិន ចាន់នី**
*អភិបាលប្រតិបត្តិ*



**លោក រ័ត្ន យូម៉េង**
*អភិបាលប្រតិបត្តិ*



**លោក Stéphane Mangiavacca**
*អភិបាលមិនប្រតិបត្តិ*



**លោក Kyosuke Hattori**
*អភិបាលមិនប្រតិបត្តិ*



**លោក Albertus Bruggink**
*អភិបាលមិនប្រតិបត្តិ*



**លោក កាយ ឡូត**
*អភិបាលមិនប្រតិបត្តិ*



**លោក Pieter Kooi**
*អភិបាលឯករាជ្យ*



**លោក វ៉ាន់ ស៊ូអៀង**
*អភិបាលឯករាជ្យ*



**លោកស្រី ភូរិ រតនា**
*អភិបាលឯករាជ្យ*

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

តាងនាមឱ្យធនាគារ អេស៊ីលីដា ភីអិលស៊ី (“ធនាគារ”) និងក្រុមប្រឹក្សាភិបាល ខ្ញុំបាទមានកិត្តិយស និងសេចក្តីសោមនស្សរីករាយ សូមផ្តល់ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសទី៣ ឆ្នាំ២០២២ របស់ធនាគារ គិតចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ ដល់ភាគីពាក់ព័ន្ធទាំងអស់។

ចាប់ពីដើមឆ្នាំ២០២២ ស្ថានភាពសេដ្ឋកិច្ចពិភពលោកពុំមានស្ថិរភាព និងបង្កក្តីព្រួយបារម្ភពីវិបត្តិជាសកល ដោយសារការកើនឡើងអតិផរណា ការរឹតត្បិតគោលនយោបាយរូបិយវត្ថុបម្រុងរបស់សហព័ន្ធ ការបន្តរាំងស្ទះខ្សែច្រវាក់ផ្គត់ផ្គង់ ការផ្ទុះឡើងជំងឺកូវីដ-១៩ និងការអូសបន្លាយសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន។ ការរឹតបន្តឹងនេះបណ្តាលមកពីការកើនឡើងលើសពីការរំពឹងទុកនៃកម្រិតអតិផរណាគោលដៅ។ សម្ពាធអតិផរណាបានធ្វើឱ្យកើនឡើងនូវថ្លៃអាហារ និងថាមពល នៅស្ទើរគ្រប់ទីកន្លែង ព្រមទាំងអាជីវកម្មកំពុងចំណាយខ្ពស់លើថ្លៃថាមពល ដឹកជញ្ជូន និងពលកម្ម។ លើសពីនេះទៀត តម្លៃទំនិញកាន់តែខ្ពស់ និងការរាំងស្ទះខ្សែច្រវាក់ផ្គត់ផ្គង់ ក៏បណ្តាលមកពីការអូសបន្លាយសង្គ្រាមនៅអ៊ុយក្រែន និងការបិទខ្ទប់នៅប្រទេសចិនតាមគោលនយោបាយគ្មានកូវីដ-១៩។

ស្ថានភាពសេដ្ឋកិច្ចកម្ពុជាបានស្ទុះងើបឡើងវិញបន្តិចម្តងៗ ទៅរកភាពប្រក្រតីវិញ លឿនជាងការរំពឹងទុកក្នុងឆ្នាំ២០២១។ កំណើននេះត្រូវបានជំរុញដោយវិធានការ និងគោលនយោបាយដ៏មានប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាល ព្រមទាំងការកើនឡើងយ៉ាងខ្លាំងក្នុងវិស័យកាត់ដេរ កសិកម្ម ទេសចរណ៍ ហិរញ្ញវត្ថុ និងធនាគារ និងវិស័យផ្សេងៗ។

នៅក្នុងកំលុងត្រីមាសទី៣ ឆ្នាំ២០២២នេះ ធនាគារបាន និងកំពុងបន្តពង្រីកផលិតផល និងសេវាកម្មចម្រុះរបស់ខ្លួន ដើម្បីបំពេញតម្រូវការអតិថិជនក្នុងការធ្វើប្រតិបត្តិការ និងការទូទាត់ប្រចាំថ្ងៃតាមធនាគារ ដែលនៅជិតខ្លួនបំផុត។ ធនាគារបាន និងកំពុងធ្វើឱ្យប្រសើរឡើងជាបន្តបន្ទាប់នូវ**អេស៊ីលីដាម៉ូបាល**របស់ខ្លួន ព្រមទាំងបំពាក់ម៉ាស៊ីនអេធីអឹមដកប្រាក់និងដាក់ប្រាក់ ម៉ាស៊ីនឆូតកាត និងសេវាធនាគារស្វ័យប្រវត្តិ ជាដើម បន្ថែមលើបណ្តាញប្រតិបត្តិការសាខាធនាគារដ៏ធំបំផុតដែលមានស្រាប់។ ទន្ទឹមនឹងនេះ ធនាគារក៏ទទួលបានការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច និងការអនុញ្ញាតជាគោលការណ៍ឱ្យធនាគារធ្វើអាជីវកម្មជាឈ្មួញជើងសាមូលបត្ររដ្ឋ សម្រាប់វិនិយោគិនមូលបត្ររដ្ឋ ដែលមិនមែនជាគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ បន្ថែមលើនេះទៀត ធនាគារ អេស៊ីលីដា ត្រូវបានជ្រើសរើសជាធនាគារទំនាក់ទំនង (Sponsoring Bank) សម្រាប់ការទូទាត់ប្រាក់រៀលឆ្លងដែនតាមរយៈឃ្យូអរកូដ ជាមួយនឹងប្រទេសជិតខាងនៅក្នុងតំបន់អាស៊ាន រួមមាន ប្រទេសវៀតណាម និងឡាវ បន្ថែមពីលើប្រទេសថៃ ដើម្បីលើកកម្ពស់ការទូទាត់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយនៅតាមបណ្តាប្រទេសជាសមាជិកអាស៊ាន និងដើម្បីជំរុញបរិយាប័ន្នហិរញ្ញវត្ថុអាស៊ានស្របតាមទិសដៅសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC)។

នៅក្នុងកំលុងត្រីមាសទី៣ ឆ្នាំ២០២២នេះ ធនាគារសម្រេចបាននូវលទ្ធផលជាវិជ្ជមាន ដោយទ្រព្យសកម្មសរុបបានកើនឡើងចំនួន ៣៦,៩៦លានដុល្លារអាមេរិក (០,៤៤%) បើធៀបនឹងត្រីមាសទី២ ឆ្នាំ២០២២។ ទន្ទឹមនឹងនេះ សមតុល្យឥណទានសរុបបានកើនឡើងដល់ចំនួន ៦.២៤២,៨៨លានដុល្លារអាមេរិក ដោយកើនឡើងពី ៦.០០២,៥០លានដុល្លារអាមេរិក នៅក្នុងត្រីមាសទី២ ឆ្នាំ២០២២។

ធនាគារទទួលបានប្រាក់ចំណេញដែលផ្តល់ជូនភាគហ៊ុនិករបស់ធនាគារ (សម្រាប់ខែកក្កដា សីហា និងកញ្ញា ឆ្នាំ២០២២) សរុបចំនួន ៤៩,៤៤លានដុល្លារអាមេរិក ខណៈដែលអនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យមមានចំនួន០,៥៩% និងអនុបាតចំណេញធៀបនឹងមូលធនមធ្យមមានចំនួន ៤,០១%។

ជាទីបញ្ចប់ ខ្ញុំបាទសូមថ្លែងអំណរគុណ និងសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅ ចំពោះភាគីពាក់ព័ន្ធទាំងអស់ដែលបានបន្តផ្តល់ការជ្រោមជ្រែង និងការគាំទ្រដល់ធនាគារ។

ថ្ងៃសុក្រ ៣រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២២
ហត្ថលេខា និងត្រា

**ឆាយ សឿន**

# មាតិកា


ព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ i

ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ ii

សមាសភាពក្រុមប្រឹក្សាភិបាល ........ v

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ........ vi

**ផ្នែកទី១- ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ ........ ១**

**ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ ........ ១**

**ខ- លក្ខណៈនៃធុរកិច្ច ........ ១**

**គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ........ ១**

**ផ្នែកទី២- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ........ ៣**

**ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក ........ ៣**

**ខ- រចនាសម្ព័ន្ធចំណូល ........ ៦**

**ផ្នែកទី៣- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យ ........ ៧**

**ផ្នែកទី៤- ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ........ ៧**

**ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ........ ៧**

**ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ........ ១០**

**គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ........ ១២**

**ឃ- ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ........ ១២**

**ង- ផលប៉ះពាល់នៃអតិផរណា ........ ១៣**

**ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល ........ ១៣**

**ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ........ ១៥**

# ផ្នែកទី១- ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ

## ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | **ធនាគារ អេស៊ីលីដា ភីអិលស៊ី** |
| ជាអក្សរឡាតាំង | **ACLEDA Bank Plc.** |
| លេខកូដស្តង់ដារ | KH១០០០១០០០០៣ |
| ទីស្នាក់ការ | អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | +៨៥៥ (០)២៣ ៩៩៨ ៧៧៧ / ៤៣០ ៩៩៩ |
| លេខទូរសារ | +៨៥៥ (០)២៣ ៤៣០ ៥៥៥ |
| គេហទំព័រ | www.acledabank.com.kh |
| អ៊ីម៉ែល | acledabank@acledabank.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០៣០៧៧ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០០ ចេញដោយក្រសួងពាណិជ្ជកម្ម |
| លេខអាជ្ញាបណ្ណអាជីវកម្ម | ០៦ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦ ចេញដោយ ធនាគារជាតិ នៃ កម្ពុជា |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | លេខ០៥៣/២០គ.ម.ក./ស.ស.រ. ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ ចេញដោយនិយ័តករមូលបត្រកម្ពុជា “ន.ម.ក.” (ពីមុនជា គណៈកម្មការមូលបត្រកម្ពុជា “គ.ម.ក.”) |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូលបត្រ | **បណ្ឌិត អ៊ិន ចាន់នី** |

## ខ- លក្ខណៈនៃធុរកិច្ច

ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺជាធនាគារពាណិជ្ជដែលមានសាខា និងបណ្តាញការិយាល័យធំជាងគេបង្អស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ធនាគារបានចុះបញ្ជីនៅក្នុងផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) ចាប់តាំងពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០។ បច្ចុប្បន្ននេះ ធនាគារមានក្រុមហ៊ុនបុត្រសម្ព័ន្ធចំនួន៤ រួមមាន៖ (១) ធនាគារ អេស៊ីលីដា ឡាវ លីមីតធីត (២) ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា (៣) ក្រុមហ៊ុន អេស៊ីលីដា ស៊ីយ្យូរីធី ភីអិលស៊ី និង (៤) វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ព្រមទាំងមានការិយាល័យតំណាងចំនួន១នៅប្រទេសមីយ៉ាន់ម៉ា។

## គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

- នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២ ធនាគារបានរៀបចំជំនួបធុរកិច្ចវិស័យកសិកម្ម នៅការិយាល័យកណ្តាលរបស់ធនាគារ អេស៊ីលីដា ដែលមានអ្នកចូលរួមជាវិនិយោគិនជាតិ និងអន្តរជាតិ ដើម្បីពង្រីកបណ្តាញធុរកិច្ច និងឱកាសវិនិយោគក្នុងវិស័យកសិកម្មនៅកម្ពុជា។
- នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២ ធនាគារ និងធនាគារ Sumitomo Mitsui Banking Corporation (SMBC) បានប្រារព្ធខួប១០ឆ្នាំ នៃភាពជាដៃគូយុទ្ធសាស្ត្រ នៅការិយាល័យកណ្តាលធនាគារ អេស៊ីលីដា។ ក្នុងកំលុង១០ឆ្នាំនេះ ធនាគារ SMBC បានផ្តល់ការគាំទ្រដល់ធនាគារគ្រប់កម្រិត ចាប់ពីថ្នាក់គ្រប់គ្រង ក្រុមប្រឹក្សាភិបាល និងភាគហ៊ុនិក ព្រមទាំងផ្តល់ការបណ្តុះបណ្តាលដោយផ្ទាល់ដល់និយោជិតរបស់ធនាគារ ព្រមទាំងរៀបចំ និងសម្របសម្រួលទស្សនកិច្ចដល់ទីកន្លែង និងបណ្តុះបណ្តាលស្តីពី

សេវាកម្មធនាគារអេឡិចត្រូនិក (EBS) និងធនាគារឌីជីថល សម្រាប់ក្រុមបច្ចេកទេសរបស់ធនាគារ នៅតាមបណ្តាធនាគារឌីជីថលជាច្រើននៅក្នុងតំបន់។

- នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២២ ធនាគារទទួលបានការអនុញ្ញាតពីនិយ័តករបរធនបាលកិច្ច (ន.ប.ធ.) ជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច សម្រាប់ប្រតិបត្តិការបរធនបាលកិច្ចសាធារណៈ បរធនបាលកិច្ចហិរញ្ញវត្ថុ បរធនបាលកិច្ចពាណិជ្ជកម្ម បរធនបាលកិច្ចសង្គម និងបរធនបាលកិច្ចបុគ្គល។ វាគឺជាសេវាកម្មមួយរបស់ធនាគារ ដើម្បីផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច ជូនបរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច បរធនបាល បុគ្គលផ្តល់សេវាពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច និងសាធារណជន ដែលមានបំណងប្រើប្រាស់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) ក្នុងវិស័យបរធនបាលកិច្ច ប្រកបដោយសុវត្ថិភាព វិជ្ជាជីវៈ និងប្រសិទ្ធភាពខ្ពស់។
- នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២ និយ័តករមូលបត្រកម្ពុជា (ន.ម.ក.) បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការជំរុញការយល់ដឹងដល់វិនិយោគិនក្នុងវិស័យមូលបត្រ ដល់ថ្នាក់គ្រប់គ្រង និងបុគ្គលិករបស់ធនាគារ អេស៊ីលីដា។
- នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២ ធនាគារបានដាក់ឱ្យដំណើរការសៀវភៅទី២ របស់ធនាគារ “**Beyond Borders, Beyond Banking**” ពិព័ណ៌នាអំពីប្រវត្តិរបស់ធនាគារ អេស៊ីលីដា ពីឆ្នាំ២០០៥-២០១៩ ដែលប្រារព្ធធ្វើឡើងនៅវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ដែលមានអ្នកតំណាងជាច្រើនមកពីស្ថាប័នរដ្ឋ និងឯកជន បានចូលរួម ព្រមទាំងមានវត្តមានរបស់លោកស្រី Heather Clark ដែលជាអ្នកនិពន្ធសៀវភៅនេះផងដែរ។
- នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២ និយ័តករមូលបត្រកម្ពុជា (ន.ម.ក.) បានអនុញ្ញាតជាគោលការណ៍ឱ្យធនាគារដែលជាភ្នាក់ងាររក្សាសុវត្ថិភាពមូលបត្រក្នុងវិស័យមូលបត្រ ធ្វើអាជីវកម្មមូលបត្ររដ្ឋ។ ការអនុញ្ញាតជាគោលការណ៍នេះ អាចឱ្យធនាគារធ្វើអាជីវកម្មជាឈ្នួញជើងសាមូលបត្ររដ្ឋ សម្រាប់វិនិយោគិនមូលបត្ររដ្ឋ ដែលមិនមែនជាគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។
- នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២ ធនាគារ និងសមាគមន៍ធុរកិច្ចជប៉ុនប្រចាំនៅកម្ពុជា (JBAC) បានរៀបចំព្រឹត្តិការណ៍ជំនួបធុរកិច្ចលើប្រធានបទ “ជំនួបពិភាក្សាជាមួយអ្នកជំនួញជោគជ័យក្នុងប្រទេសកម្ពុជា” នៅការិយាល័យកណ្តាលរបស់ធនាគារ អេស៊ីលីដា ដែលមានបណ្តាក្រុមហ៊ុនជប៉ុនប្រមាណជាង៥០ បានចូលរួមបើកវេទិកាពិភាក្សាស្វែងយល់ពីចំណុចសំខាន់ៗ នៃសក្តានុពលសេដ្ឋកិច្ច និងការលើកទឹកចិត្តដើម្បីជំរុញវិនិយោគិនជប៉ុនផ្សេងទៀតមកវិនិយោគនៅក្នុងប្រទេសកម្ពុជា។ ក្នុងជំនួបនេះ វិនិយោគិនជប៉ុនមានឱកាសជួបគ្នាទៅវិញទៅមក និងស្វែងរកឱកាសវិនិយោគនៅកម្ពុជា ដើម្បីឱ្យមានភាពរីកចម្រើនទាំងអស់គ្នា។
- នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២២ ធនាគារជាតិ នៃ កម្ពុជា បានជ្រើសរើសធនាគារ អេស៊ីលីដា ជា **ធនាគារទំនាក់ទំនង សម្រាប់ការទូទាត់ប្រាក់រៀលឆ្លងដែនតាមរយៈឃ្យូអរកូដ** ជាមួយប្រទេសជិតខាងនៅក្នុងតំបន់អាស៊ាន រួមមាន ប្រទេសវៀតណាម និងឡាវ។ នេះគឺជាការបន្ថែមទៅលើការទូទាត់ឆ្លងដែនតាមរយៈឃ្យូអរកូដជាមួយប្រទេសថៃ ដែលត្រូវបានដាក់ឱ្យដំណើរការនៅខែកុម្ភៈ ឆ្នាំ២០២០ ដើម្បីលើកកម្ពស់ការទូទាត់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយនៅតាមបណ្តាប្រទេសជាសមាជិកអាស៊ាន និងដើម្បីជំរុញបរិយាប័ន្នហិរញ្ញវត្ថុអាស៊ានស្របតាមទិសដៅ សមាហរណកម្មសមាគមន៍សេដ្ឋកិច្ចអាស៊ាន (AEC)។
- នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២ **បណ្ឌិត អ៊ិន ចាន់នី** ប្រធាននាយកប្រតិបត្តិ ធនាគារ អេស៊ីលីដា ភីអិលស៊ី បានទទួលពានរង្វាន់អ្នកដឹកនាំធុរកិច្ចឆ្នើមប្រចាំតំបន់អាស៊ាន (ASEAN Outstanding Distinguished Business Leader Lifetime Achievement Award) ពីវិទ្យាស្ថានយុទ្ធសាស្ត្រសម្រាប់អាស៊ីប៉ាស៊ីហ្វិក (Strategic Institute for Asia Pacific) ក្នុងវេទិកាភាពជាអ្នកដឹកនាំ និងដៃគូអាស៊ាន ក្នុងឆ្នាំ២០២២ ដែលរៀបចំឡើងនៅថ្ងៃទី១១ និង១២ ខែកញ្ញា ឆ្នាំ២០២២ នៅរាជធានីភ្នំពេញ។ ពានរង្វាន់នេះបានប្រគល់ជូនជ័យលាភីមិនលើសពី២០រូប អញ្ជើញមកពីបណ្តាប្រទេសអាស៊ានទាំង១០។ ពានរង្វាន់នេះបញ្ជាក់ពីភាពជាអ្នកដឹកនាំធុរកិច្ច ភាពជាសហគ្រិនឆ្នើម និងការចូលរួមចំណែកក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជា និងក្នុងតំបន់អាស៊ាន។
- នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ ធនាគារបានទទួលលិខិតថ្លែងអំណរគុណពីវេទិកាហិរញ្ញប្បទានសហគ្រាសធុនតូច និងមធ្យមសកលលោក សម្រាប់ការរៀបចំទស្សនកិច្ចសិក្សា សម្រាប់ថ្នាក់គ្រប់គ្រងចូលរួមក្នុងវេទិកាហិរញ្ញប្បទានសហគ្រាសធុនតូច និងមធ្យម ឆ្នាំ២០២២។ គណៈគ្រប់គ្រងរបស់ធនាគារ ដែលដឹកនាំដោយ**បណ្ឌិត អ៊ិន ចាន់នី ប្រធាននាយកប្រតិបត្តិ**

**ធនាគារ អេស៊ីលីដា ភីអិលស៊ី** បានស្វាគមន៍យ៉ាងកក់ក្ដៅចំពោះគណៈប្រតិភូ Global SME Finance ដែលបានធ្វើទស្សនកិច្ច នៅការិយាល័យកណ្ដាលរបស់ធនាគារ អេស៊ីលីដា ដើម្បីសិក្សាស្វែងយល់អំពីការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ក្នុងវិស័យ ធនាគារនៅកម្ពុជា ជាពិសេស ធនាគារ អេស៊ីលីដា ដែលបានចូលរួមចំណែកក្នុងការជួយជំរុញកំណើនសេដ្ឋកិច្ចជាតិប្រកបដោយ និរន្តរភាព។

- នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២២ ធនាគារបានទទួលលិខិតថ្លែងអំណរគុណពីវេទិកាហិរញ្ញប្បទានសហគ្រាសធុនតូច និងមធ្យម សម្រាប់ការឧបត្ថម្ភកម្មវិធីវេទិកាហិរញ្ញប្បទានសហគ្រាសធុនតូច និងមធ្យមសកលលោក ឆ្នាំ២០២២។ បុព្វហេតុចម្បងនៃ ការចូលរួមឧបត្ថម្ភរបស់ធនាគារ សម្រាប់វេទិកាហិរញ្ញប្បទានសហគ្រាសធុនតូច និងមធ្យមសកលលោកនេះ គឺ ១) ដើម្បី ផ្សព្វផ្សាយដៃគូធុរកិច្ច សម្រាប់បរិយាប័ន្នហិរញ្ញវត្ថុ ស្របតាមបេសកកម្មស្នូលរបស់ធនាគារ អេស៊ីលីដា និង ២) របៀបវារៈនៃវេទិកា ហិរញ្ញប្បទានសហគ្រាសធុនតូច និងមធ្យមសកលលោក លើកទី៩នេះ ស្ដីពី “**តំណភ្ជាប់ទៅនឹងឌីជីថលនីយកម្ម សម្រាប់ ហិរញ្ញប្បទានធុនតូច និងមធ្យម ប្រកបដោយបរិយាប័ន្ន និងនិរន្តរភាព**” ស្របតាមដំណើរការនៃការកម្លាយខ្លួនទៅជា ធនាគារឌីជីថលរបស់ធនាគារ អេស៊ីលីដា។
- នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២២ **ធនាគារ អេស៊ីលីដា ភីអិលស៊ី** បានទទួលពានរង្វាន់ “**ហិរញ្ញប្បទានសហគ្រាសធុនតូច និងមធ្យមសកលលោក ឆ្នាំ២០២២ ជាស្ថាប័នដែលផ្ដល់ហិរញ្ញប្បទានដល់សហគ្រាសធុនតូច និងមធ្យមប្រចាំឆ្នាំ**” ក្នុងវេទិកាហិរញ្ញប្បទានសហគ្រាសធុនតូច និងមធ្យមសកលលោក លើកទី៩ ដែលរៀបចំឡើងដោយស្ថាប័នសាជីវកម្មហិរញ្ញវត្ថុ អន្តរជាតិ (IFC) និងសហការរៀបចំដោយធនាគារជាតិ នៃ កម្ពុជា ក្នុងគោលបំណងពង្រីកនូវលទ្ធភាពទទួលបានហិរញ្ញប្បទាន សម្រាប់សហគ្រាសធុនតូច និងមធ្យមទូទាំងសកលលោក។ ធនាគារមានមោទនភាពយ៉ាងក្រៃលែង ដែលបានទទួលពានរង្វាន់ នេះ។ ទាំងនេះសបញ្ជាក់ថា ធនាគារបានធ្វើការប្ដេជ្ញាចិត្ត ប្រកបដោយនិរន្តរភាពក្នុងការផ្ដល់ហិរញ្ញប្បទានដល់សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា។
- នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២ ធនាគារបានទទួលពានរង្វាន់ "**ដៃគូធនាគារល្អបំផុត សម្រាប់សហគ្រាសធុនតូច និង មធ្យម នៅក្នុងតំបន់អាស៊ីខាងកើត និងប៉ាស៊ីហ្វិក**" ពីស្ថាប័នសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ដោយសារធនាគារបាន និង កំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងសហគ្រាសធុនតូច និងមធ្យម និងបម្រើនូវផលិតផល-សេវាកម្មហិរញ្ញវត្ថុចម្រុះយ៉ាងសម្បូរបែប ជាពិសេសសេវាកម្មធនាគារអេឡិចត្រូនិក និងឌីជីថល ប្រកបដោយភាពងាយស្រួល និងសុវត្ថិភាព ដើម្បីឆ្លើយតបនឹងតម្រូវការ របស់អតិថិជន។ លើសពីនេះ ធនាគារ អេស៊ីលីដា បានផ្ដល់ហិរញ្ញប្បទានយ៉ាងច្រើនដល់សហគ្រាសធុនតូច និងមធ្យម ដើម្បី រួមចំណែកក្នុងការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ប្រកបដោយនិរន្តរភាព។
- នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ ធនាគារបានទទួលវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទ “**មាស**” ដែលមានសុពល ភាពសម្រាប់រយៈពេល២ឆ្នាំ (២០២២ និង ២០២៣) ពីអគ្គនាយកដ្ឋានពន្ធដារ សម្រាប់ការអនុវត្តការបង់ពន្ធអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។
- នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ ធនាគារបានទទួល “**ពានរង្វាន់ឈានមុខផ្នែកនវានុវត្តន៍ទិន្នន័យ**” ពីក្រុមហ៊ុនក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី នៅក្នុងឱកាសខួប១០ឆ្នាំ របស់ក្រុមហ៊ុនក្រេឌីត ប្យូរ៉ូ (ខេមបូឌា)។ ធនាគារមានមោទនភាពយ៉ាងក្រៃលែង ដែលបានទទួលពានរង្វាន់នេះ ដោយសារធនាគារឈានមុខគេផ្នែកនវានុវត្តន៍ទិន្នន័យនៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ ជាពិសេសប្រសិទ្ធភាពក្នុងការចែករំលែកព័ត៌មានឥណទាននៅកម្ពុជា។

## ផ្នែកទី២- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

### ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

- **<u>ប្រតិបត្តិការក្នុងវិស័យធនាគារ</u>**

ត្រឹមដំណាច់ខែកញ្ញា ឆ្នាំ២០២២ ធនាគារពាណិជ្ជមានចំនួន៥៩ (ធនាគារក្នុងស្រុកចំនួន២៧ បុត្រសម្ព័ន្ធធនាគារបរទេសចំនួន១៨ និងសាខាធនាគារបរទេសចំនួន១៤) ធនាគារឯកទេសចំនួន០៩ (ធនាគារក្នុងស្រុកចំនួន០៤ និងធនាគារបរទេសចំនួន០៥) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៨៧ (គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន០៥ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់

បញ្ញើចំនួន៨២) ក្រុមហ៊ុនភតិសន្យាចំនួន១៦ ការិយាល័យតំណាងធនាគារបរទេសចំនួន០៦ គ្រឹះស្ថានផ្ដល់សេវាទូទាត់សងប្រាក់ចំនួន៣៤ និងគ្រឹះស្ថានឥណទានជនបទចំនួន២២៦។ (Source: NBC Report, CMA Report, and Actually Updated)

- **ប្រតិបត្តិការអាជីវកម្ម និងចំណែកទីផ្សាររបស់ធនាគារ អេស៊ីលីដា នៅក្នុងវិស័យធនាគារ**

គិតត្រឹមដំណាច់ខែកក្កដា ឆ្នាំ២០២២ ធនាគារ អេស៊ីលីដា ភីអិលស៊ី មានចំណែកទីផ្សារសម្រាប់ប្រាក់បញ្ញើសន្សំចំនួន ១៥,៦៩% និងសម្រាប់ឥណទានចំនួន ១៣,៣០%។

គិតត្រឹមដំណាច់ខែកញ្ញា ឆ្នាំ២០២២ ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួនទទួលបានលទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ត្រីមាសទី៣ ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ |
| **សេវាឥណទាន** | | | |
| ចំនួនឥណទានសកម្ម | ៥៧៦.២៣៤ | ៥៤១.១៨៤ | ៥៥៥.៣២៣ |
| សមតុល្យឥណទានសរុប (លានរៀល) | ២៥.៧១៤.៤៤០ | ២២.១១៦.០១៣ | ១៨.២២៩.៣៧២ |
| **សេវាបញ្ញើ-សន្សំ** | | | |
| ចំនួនគណនីសរុប | ៣.៧៣៣.៧៥៨ | ៣.២៩៨.៣៨២ | ២.៨៩៤.៩០៧ |
| សមតុល្យប្រាក់បញ្ញើសរុប (លានរៀល) | ២៤.២៩៦.៤៧១ | ២៣.២៨៧.០៦៤ | ១៨.៦៥២.៦៩០ |
| **សេវាធនាគារអេឡិចត្រូនិក** | | | |
| **ប័ណ្ណអេធីអឹមអេស៊ីលីដា** | | | |
| ចំនួនប័ណ្ណបោះផ្សាយសរុប | ១.៧៦៥.៦៩០ | ១.៥៨៥.៨៤៩ | ១.៣៩៦.៧៧៨ |
| ចំនួនប្រតិបត្តិការសរុប | ១៥.៨៤០.៤៨២ | ១៩.៤៤៨.៨៣៧ | ១៩.៧៦៨.២២៣ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១៤.៣០៥.៩៥៩ | ១៦.១៧៣.៩៩០ | ១៣.៧៧៥.៩១៨ |
| **អេស៊ីលីដាម៉ូបាល** | | | |
| ចំនួនអ្នកប្រើប្រាស់សរុប | ២.៧៤៨.៤២៨ | ២.២៧៨.២២០ | ១.៧៨២.៨១៤ |
| ចំនួនប្រតិបត្តិការសរុប | ៩៩.៣២២.៤៧២ | ៧៨.៧២៦.៨៩៥ | ៤៨.៧៤៩.៥៩៩ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១៤៥.៩៩២.១៨០ | ១១៥.២៤២.៦៣៨ | ៥៩.២១១.២៧៩ |
| **អេស៊ីលីដាអ៊ីនធើណែត** | | | |
| ចំនួនអ្នកប្រើប្រាស់សរុប | ២១.៤២៧ | ១៣.៥៥៧ | ១១.៦៧៩ |
| ចំនួនប្រតិបត្តិការសរុប | ១.៦៦៤.០៨២ | ១.៤៦៦.៨២២ | ៨៨៦.៩៩០ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១៩.៦៥២.២៣៨ | ១៩.៧៩៩.៨៦៤ | ១១.២៨៥.៩៤៨ |
| **អេស៊ីលីដាអ៊ីខុមមើស** | | | |
| ចំនួនដៃគូអាជីវកម្មសរុប | ៦៥ | ៥៩ | ៥១ |
| ចំនួនប្រតិបត្តិការសរុប | ២.៧១៣.៨៧០ | ៣.២១៥.២០៧ | ៤៤៧.៩២៩ |

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ត្រីមាសទី៣ ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១.៣៣២.១៨៥ | ១.២០៦.៥២៩ | ៣៦០.០០០ |
| **ម៉ាស៊ីនអេធីអឹមអេស៊ីលីដា** | | | |
| ចំនួនម៉ាស៊ីនសរុប | ១.១១០ | ៩០១ | ៧៥៧ |
| ចំនួនប្រតិបត្តិការសរុប | ២៥.៨៧៦.៥៨៩ | ២៧.១២៩.២៥២ | ២៦.៥៧២.៧៧១ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ២៨.៩២៩.៨៥៣ | ២៦.៤៧៧.៣៨១ | ២០.០១៨.៤៣២ |
| **ម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់** | | | |
| ចំនួនម៉ាស៊ីនសរុប | ២៦ | ២៦ | ១៤ |
| ចំនួនប្រតិបត្តិការសរុប | ១.៣២៤ | ៤.១២០ | ១.៩០៧ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១០១.៨១៧ | ៣៨៣.១៥៨ | ១៨០.២៩២ |
| **ម៉ាស៊ីនបើកគណនី និងបោះពុម្ពប័ណ្ណអេធីអឹម** | | | |
| ចំនួនម៉ាស៊ីនសរុប | ២៤ | ២៥ | - |
| ចំនួនប្រតិបត្តិការសរុប | ៣២.៩១៣ | ៣៤.០៩២ | - |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១៥ | ៧០ | - |
| **ម៉ាស៊ីនទទួលកាបូបប្រាក់** | | | |
| ចំនួនម៉ាស៊ីនសរុប | ១២ | ១៤ | ១៩ |
| ចំនួនប្រតិបត្តិការសរុប | ៥៥.០៥៦ | ៩៤.៧១៣ | ១២១.១៩៨ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៤២៧.៩០៦ | ៥៥៥.២៥៧ | ៨៣០.៤០៨ |
| **ម៉ាស៊ីនឆូតកាតអេស៊ីលីដា** | | | |
| ចំនួនម៉ាស៊ីនឆូតកាតសរុប | ៤.២២៣ | ៤.៤៦២ | ៤.២៨៧ |
| ចំនួនប្រតិបត្តិការសរុប | ១.៦៥០.៣៨៨ | ២.០៣៣.២៨៣ | ២.៤៥៧.៦២៦ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៤៤២.០៣៤ | ៤៧៩.៦១៣ | ៦៥៧.៥០៦ |
| **កូដ QR នៅតាមហាងទំនិញនានា** | | | |
| ចំនួនពាណិជ្ជករបំពាក់កូដ QR | ២១៣.៧៨០ | ១២៥.៣០៩ | ៦៣.៧១៤ |
| ចំនួនប្រតិបត្តិការសរុប | ៨.៩៧៥.៤១៩ | ៣.១៩៤.៤៤៣ | ១.៨៤២.៩១៣ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ២.៩៩៨.២១១ | ៦៣៨.២៤០ | ១៨៦.៦៩១ |
| **អេស៊ីលីដាអ៊ីសប** | | | |
| ចំនួនផ្សារអនឡាញ | ៦ | ១ | - |

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ត្រីមាសទី៣ ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ |
| ចំនួនប្រតិបត្តិការសរុប | ១៨ | ២៨៦ | - |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ០,៣៩ | ៧ | - |
| **ប័ណ្ណនិម្មិតអេស៊ីលីដា** | | | |
| ចំនួនប័ណ្ណនិម្មិត | ៥.៦០៧ | ៣.៦៨៤ | - |
| ចំនួនប្រតិបត្តិការសរុប | ២០.៧៨៣ | ២.៨៩១ | - |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១.៦៥៨ | ១៦១ | - |
| **ខ្មែរអាយប៊ែង** | | | |
| ចំនួនខ្មែរបោះផ្សាយសរុប | ៤.៧៨២ | - | - |
| ចំនួនប្រតិបត្តិការសរុប | ២.៨១១ | - | - |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ២.៥១១ | - | - |
| **បណ្តាញប្រតិបត្តិការ និង បុគ្គលិក** | | | |
| **ធនាគារ អេស៊ីលីដា ភីអិលស៊ី** | | | |
| ចំនួនការិយាល័យសរុប | ២៦៣ | ២៦២ | ២៦៣ |
| ចំនួនធនាគារស្វ័យប្រវត្តិ | ១១៤ | ៧៣ | ៣៧ |
| ចំនួនបុគ្គលិកសរុប | ១២.០៩៦ | ១២.០៨១ | ១២.០១៣ |
| **ក្រុមហ៊ុនបុត្រសម្ព័ន្ធ (ក្នុង និង ក្រៅប្រទេស)** | | | |
| ចំនួនការិយាល័យសរុប | ៥៦ | ៥៧ | ៥៦ |
| ចំនួនបុគ្គលិកសរុប | ១.៥៣៥ | ១.៥៩៣ | ១.៦៩១ |

## ខ- រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល (លានរៀល) | ត្រីមាសទី៣ ឆ្នាំ២០២២ | | ត្រីមាសទី៣ ឆ្នាំ២០២១ | | ត្រីមាសទី៣ ឆ្នាំ២០២០ | |
|---|---|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ១ | ចំណូលការប្រាក់ | ៧០១.៧៩២ | ៩០,៣៧% | ៥៩៥.៣៦៨ | ៩០,៦៣% | ៥២៣.៥១១ | ៨៩,៦០% |
| ២ | ចំណូលកម្រៃនិងជើងសា | ៥០.៣៩៦ | ៦,៤៩% | ៤២.៦៧៥ | ៦,៥០% | ៤៦.៥៤៨ | ៧,៩៧% |
| ៣ | ចំណូលផ្សេងៗសុទ្ធ | ២៤.៣៤៨ | ៣,១៤% | ១៨.៨៤៩ | ២,៨៧% | ១៤.១៨៧ | ២,៤៣% |
| **ចំណូលសរុប** | | **៧៧៦.៥៣៦** | **១០០%** | **៦៥៦.៨៩២** | **១០០%** | **៥៨៤.២៨៦** | **១០០%** |

## ផ្នែកទី៣- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យ

សូមពិនិត្យមើលឧបសម្ព័ន្ធដែលបានភ្ជាប់មកជាមួយ
របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យ

## ផ្នែកទី៤- ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងការវិភាគខាងក្រោមនេះផ្តោតសំខាន់លើលទ្ធផលប្រតិបត្តិការ និងលទ្ធផលហិរញ្ញវត្ថុដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុចន្លោះពេលគិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ ដែលត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យ។ របាយការណ៍ហិរញ្ញវត្ថុចន្លោះពេលត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ស.រ.ហ.អ.ក)។ មានតែសមាសធាតុសំខាន់ៗនៃរបាយការណ៍ហិរញ្ញវត្ថុចន្លោះពេល និងកត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ប៉ុណ្ណោះ ត្រូវបានយកមកធ្វើការពិភាក្សា និងវិភាគ។

### ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

#### ១- ការវិភាគចំណូល

ធនាគារ អេស៊ីលីដា ភីអិលស៊ី មានប្រភពចំណូលធំៗចំនួនបីគឺ ចំណូលការប្រាក់ ចំណូលកម្រៃនិងជើងសា និងចំណូលផ្សេងៗសុទ្ធ។

- ចំណូលការប្រាក់៖ រួមមានចំណូលការប្រាក់ពីឥណទាននិងបុរេប្រទាន ចំណូលការប្រាក់ពីប្រាក់បញ្ញើនៅធនាគារផ្សេងៗ និងការវិនិយោគហិរញ្ញវត្ថុ។
- ចំណូលកម្រៃនិងជើងសា៖ រួមមានកម្រៃជើងសា កម្រៃជើងសាបានពីភ្នាក់ងារធានារ៉ាប់រង កម្រៃពីម៉ាស៊ីនអេធីអឹម កម្រៃពីការសងឥណទានមុនកាលកំណត់ កម្រៃពីសេវាប្រាក់បញ្ញើ កម្រៃពីសេវាធានា និងកម្រៃពីការបណ្តុះបណ្តាល។
- ចំណូលផ្សេងៗសុទ្ធ៖ រួមមានចំណេញពីការប្តូររូបិយប័ណ្ណ ចំណេញពីការលក់ទ្រព្យនិងបរិក្ខារ ភាគលាភលើការវិនិយោគហិរញ្ញវត្ថុ និងចំណូលផ្សេងៗ។

#### ២- ការវិភាគចំណូលតាមផ្នែក

| ល.រ | ប្រភពចំណូល (លានរៀល) | ត្រីមាសទី៣ ឆ្នាំ២០២២ | | ត្រីមាសទី៣ ឆ្នាំ២០២១ | | ត្រីមាសទី៣ ឆ្នាំ២០២០ | |
|---|---|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ១ | ចំណូលការប្រាក់ | ៧០១.៧៩២ | ៩០,៣៧% | ៥៩៥.៣៦៨ | ៩០,៦៣% | ៥២៣.៥១១ | ៨៩,៦០% |
| ២ | ចំណូលកម្រៃនិងជើងសា | ៥០.៣៩៦ | ៦,៤៩% | ៤២.៦៧៥ | ៦,៥០% | ៤៦.៥៤៨ | ៧,៩៧% |
| ៣ | ចំណូលផ្សេងៗសុទ្ធ | ២៤.៣៤៨ | ៣,១៤% | ១៨.៨៤៩ | ២,៨៧% | ១៤.១៨៧ | ២,៤៣% |
| | **ចំណូលសរុប** | **៧៧៦.៥៣៦** | **១០០%** | **៦៥៦.៨៩២** | **១០០%** | **៥៨៤.២៤៦** | **១០០%** |

ចំណូលសរុបចំនួន ៧៧៦,៥៤ ប៊ីលានរៀល ក្នុងត្រីមាសទី៣ ឆ្នាំ២០២២ ភាគច្រើនបានមកពីចំណូលការប្រាក់ដែលមានចំណែក ៩០,៣៧% នៃចំណូលសរុប និងចំណូលសរុបបានកើនឡើងចំនួន ១១៩,៦៤ ប៊ីលានរៀល ឬ ១៨,២១% បើប្រៀបធៀបទៅនឹងត្រីមាសទី៣ ឆ្នាំ២០២១។

## ៣- ការវិភាគគម្លាតចំណេញដុល

របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរបស់ធនាគារ បានរៀបចំក្នុងទម្រង់ជារបាយការណ៍ដែលមិនបង្ហាញពីគម្លាតចំណេញដុលទេ។ ចំណូលការប្រាក់សុទ្ធដែលទទួលបានមកពីចំណូលការប្រាក់សរុបដកនឹងចំណាយការប្រាក់សរុប នឹងត្រូវយកមកបង្ហាញនៅក្នុងការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ ដូចខាងក្រោម។

## ៤- ការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ

| របាយការណ៍ចំណេញ ឬខាត (លានរៀល) | ត្រីមាសទី៣ ឆ្នាំ២០២២ | ត្រីមាសទី៣ ឆ្នាំ២០២១ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| ចំណូលការប្រាក់ | ៧០១.៧៩២ | ៥៩៥.៣៦៨ | ១០៦.៤២៤ | ១៧,៨៨% |
| ចំណាយការប្រាក់ | (២៣២.៧៤៩) | (១៨២.៥៩៤) | (៥០.១៥៥) | ២៧,៤៧% |
| **ចំណូលការប្រាក់សុទ្ធ** | **៤៦៩.០៤៤** | **៤១២.៧៧៤** | **៥៦.២៧០** | **១៣,៦៣%** |
| ចំណូលកម្រៃនិងជើងសា | ៥០.៣៩៦ | ៤២.៦៧៥ | ៧.៧២១ | ១៨,០៩% |
| ចំណាយកម្រៃនិងជើងសា | (៦.៦៨១) | (១.៦៧០) | (៥.០១១) | ៣០០,០៦% |
| **ចំណូលកម្រៃនិងជើងសាសុទ្ធ** | **៤៣.៧១៥** | **៤១.០០៥** | **២.៧១០** | **៦,៦១%** |
| សំវិធានធននៃការខាតបង់ឱនភាពនៃតម្លៃរបស់ឥណទាន និងបុរេប្រទាន ប្រាក់បញ្ញើនៅធនាគារផ្សេងៗ គណនីត្រូវទទួល និងមូលបត្រវិនិយោគផ្សេងៗ | (៦.១៧១) | (៣៣.៩៤៨) | ២៧.៧៧៧ | (៨១,៨២%) |
| សំវិធានធននៃការខាតបង់ឱនភាពនៃតម្លៃកិច្ចសន្យាក្រៅតារាងតុល្យការ | (៥) | (៤) | (១) | ២៥,០០% |
| **ចំណាយពីការខាតបង់ឱនភាពនៃតម្លៃសុទ្ធ** | **(៦.១៧៥)** | **(៣៣.៩៥១)** | **២៧.៧៧៦** | **(៨១,៨១%)** |
| **ចំណូលបន្ទាប់ពីការខាតបង់ឱនភាពនៃតម្លៃ** | **៥០៦.៥៨៣** | **៤១៩.៨២៧** | **៨៦.៧៥៦** | **២០,៦៦%** |
| ចំណូលផ្សេងៗសុទ្ធ | ២៤.៣៤៨ | ១៨.៨៤៩ | ៥.៤៩៩ | ២៩,១៧% |
| ចំណាយទូទៅនិងរដ្ឋបាល | (២៧៦.៩០៦) | (២៤០.១៣៩) | (៣៦.៧៦៧) | ១៥,៣១% |
| **ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ** | **២៥៤.០២៥** | **១៩៨.៥៣៧** | **៥៥.៤៨៨** | **២៧,៩៥%** |

ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញនៅត្រីមាសទី៣ ឆ្នាំ២០២២ បានកើនឡើងចំនួន ៥៥,៤៩ ប៊ីលានរៀល ឬ ២៧,៩៥% បើប្រៀបធៀបទៅនឹងត្រីមាសទី៣ ឆ្នាំ២០២១ ដោយសារភាគច្រើនមកពីការកើនឡើងនូវចំណូលការប្រាក់សុទ្ធចំនួន ៥៦,២៧ ប៊ីលានរៀល ចំណូលកម្រៃនិងជើងសាសុទ្ធចំនួន ២,៧១ ប៊ីលានរៀល និងចំណូលផ្សេងៗសុទ្ធចំនួន ៥,៥០ ប៊ីលានរៀល ខណៈដែលចំណាយពីការខាតបង់ឱនភាពនៃតម្លៃសុទ្ធថយចុះចំនួន ២៧,៧៨ ប៊ីលានរៀល និងកាត់បន្ថយដោយការកើនឡើងនូវចំណាយទូទៅនិងរដ្ឋបាលចំនួន ៣៦,៧៧ ប៊ីលានរៀល។

## ៥- ការវិភាគចំណេញ/(ខាត) ក្នុងការិយបរិច្ឆេទ

| របាយការណ៍ចំណេញ ឬខាត (លានរៀល) | ត្រីមាសទី៣ ឆ្នាំ២០២២ | ត្រីមាសទី៣ ឆ្នាំ២០២១ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| **ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ** | **២៥៤.០២៥** | **១៩៨.៥៣៧** | **៥៥.៤៨៨** | **២៧,៩៥%** |
| ចំណាយពន្ធលើប្រាក់ចំណេញ | (៥១.០០៩) | (៣៩.៨៤២) | (១១.១៦៧) | ២៨,០៣% |
| **ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ** | **២០៣.០១៦** | **១៥៨.៦៩៥** | **៤៤.៣២១** | **២៧,៩៣%** |

## ៦- ការវិភាគលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

| លទ្ធផលលម្អិតសរុប (លានរៀល) | ត្រីមាសទី៣ ឆ្នាំ២០២២ | ត្រីមាសទី៣ ឆ្នាំ២០២១ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| **ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ** | **២០៣.០១៦** | **១៥៨.៦៩៥** | **៤៤.៣២១** | **២៧,៩៣%** |
| **លទ្ធផលលម្អិតផ្សេងៗ៖** | | | | |
| **ធាតុដែលនឹងមិនត្រូវបានចាត់ថ្នាក់ឡើងវិញទៅចំណេញ ឬខាត៖** | | | | |
| ការវាស់វែងឡើងវិញនៃកាតព្វកិច្ចអត្ថប្រយោជន៍និយោជិត | ១.០៦១ | ៤៣៩ | ៦២២ | ១៤១,៦៩% |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | ៦០.៧៣១ | ៤.៦៨៦ | ៥៦.០៤៥ | ១.១៩៦,០១% |
| **ធាតុដែលត្រូវ ឬអាចត្រូវបានចាត់ថ្នាក់ឡើងវិញនៅគ្រាបន្ទាប់ទៅចំណេញ ឬខាត៖** | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ-ក្រុមហ៊ុនបុត្រសម្ព័ន្ធបរទេស | (២០.៧៣៤) | (១៩.១០២) | (១.៦៣២) | (៨,៥៤%) |
| ការវាស់វែងឡើងវិញលើផ្នែកដែលមានប្រសិទ្ធភាពរបស់ឧបករណ៍និស្សន្ទដែលកើតឡើងពីការការពារហានិភ័យលំហូរសាច់ប្រាក់ | ២៤.៦៨៧ | - | ២៤.៦៨៧ | - |
| **លទ្ធផលលម្អិតផ្សេងៗក្នុងការិយបរិច្ឆេទ** | **៦៥.៧៨៥** | **(១៣.៩៧៧)** | **៧៩.៧២២** | **៥៧០,៣៨%** |
| **លទ្ធផលលម្អិតសរុបក្នុងការិយបរិច្ឆេទ** | **២៦៨.៧៦១** | **១៤៤.៧១៨** | **១២៤.០៤៣** | **៨៥,៧១%** |

## ៧- ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

ធនាគារ អេស៊ីលីដា មានទំនុកចិត្តក្នុងការធ្វើឱ្យប្រសើរឡើងនូវប្រតិបត្តិការរបស់ខ្លួន ចំពេលការព្យាករកំណើនសេដ្ឋកិច្ចមានសញ្ញាល្អប្រសើរឡើង បន្ទាប់ពីបានកសាងកេរ្តិ៍ដំណែលដ៏រឹងមាំអស់រយៈពេល ៣០ឆ្នាំកន្លងមកនេះ ធនាគារ អេស៊ីលីដា បានត្រៀមខ្លួនរួចជាស្រេចសម្រាប់ពេលអនាគត ហើយនឹងនៅតែបន្តចាក់គ្រឹះឱ្យកាន់តែរឹងមាំដើម្បីផ្តល់ជូននូវដំណោះស្រាយក្នុងវិស័យធនាគារឱ្យកាន់តែសម្បូរបែប ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរតម្រូវការផ្នែកហិរញ្ញវត្ថុរបស់អតិថិជនទាំងនៅក្នុង និងក្រៅប្រទេសកម្ពុជា។

បន្ទាប់ពីបំបែកព្រំដែនភូមិសាស្ត្រ ដោយការដាក់បញ្ចូលនូវហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងរូបវន្ត ធនាគារដែលបានបង្កើតឡើងនៅក្នុងស្រុកមួយនេះ កំពុងផ្តល់ជូននូវសេវាកម្មធនាគារសម្រាប់មូលដ្ឋានអតិថិជនចម្រុះដោយជោគជ័យ ដែលមានរាប់ចាប់តាំងពីសេវាធនាគារបុគ្គល និងសម្រាប់សាជីវកម្ម ទាំងនៅក្នុងទីក្រុង រហូតដល់តំបន់ជនបទ។ ជាមួយនឹងភាពលេចធ្លោក្នុងការផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុដ៏សម្បូរបែប ដូចជាផ្តល់ប្រាក់កម្ចី ផ្ទេរប្រាក់ ប្រាក់បញ្ញើ ហិរញ្ញប្បទានពាណិជ្ជកម្ម អេស៊ីលីដាអ៊ីនធើណែត អេស៊ីលីដាម៉ូបាល និងសេវាសំខាន់ជាច្រើនទៀត គាំទ្រដោយហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការិយាល័យរូបវន្តរបស់ខ្លួន ធនាគារ អេស៊ីលីដា កំពុងចូលរួមយ៉ាងសកម្មក្នុងការជួយដល់កសិករ តាមរយៈការផ្តល់ដើមទុនសម្រាប់ធ្វើស្រែចម្ការរបស់គាត់ ឬផ្តល់ទុនសម្រាប់សហគ្រាសធុនតូច និងមធ្យមជាដើម។ តាមរយៈការបង្រួមគម្លាតចំពោះការទទួលបានហិរញ្ញប្បទានសព្វថ្ងៃនេះប្រជាជនកម្ពុជាច្រើនជាងកន្លះលាននាក់ មានលទ្ធភាពប្រើប្រាស់សេវារបស់ធនាគារ អេស៊ីលីដា ដែលជាការជំរុញនិងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅព្រះរាជាណាចក្រកម្ពុជា។

សម្រាប់រយៈពេល៣០ឆ្នាំខាងមុខ គេនឹងមើលឃើញ ធនាគារ អេស៊ីលីដា គឺជា ធនាគារឌីជីថល ដែលមានវិស្វកម្មគ្រប់គ្រងទិន្នន័យទំនើបទាន់សម័យ (Data Lakehouse) ប្រកបដោយគុណភាព សុវត្ថិភាព និងទំនុកចិត្ត។ ប្រព័ន្ធអេកូនៃបណ្តាញប្រកបដោយប្រសិទ្ធភាពរបស់ធនាគារនៅទូទាំងប្រទេស រួមមានម៉ាស៊ីន ATM ទីតាំងធនាគារស្វ័យប្រវត្តិ ម៉ាស៊ីនដក-ដាក់ប្រាក់ ម៉ាស៊ីនបើកគណនីនិងបោះពុម្ពប័ណ្ណអេធីអឹម ម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់ កំពុងដើរតួជាកាតាលីករដ៏មានឥទ្ធិពលមួយសម្រាប់រលកនៃកំណើនបន្ទាប់។

អនាគតរបស់ធនាគារនឹងកាន់តែរឹងមាំ ខណៈទំនុកចិត្តរបស់អាជីវកម្មលើកំណើនសេដ្ឋកិច្ចរបស់កម្ពុជានឹងកើនឡើង បន្ទាប់ពីរាជរដ្ឋាភិបាលបានទប់ស្កាត់ការរីករាលដាលនៃជំងឺរាតត្បាតកូវីដ-១៩ ប្រកបដោយប្រសិទ្ធភាពខ្ពស់។ ទស្សនៈវិស័យកំណើនរបស់ប្រទេសកម្ពុជា ត្រូវបានរំពឹងថានឹងងើបឡើងវិញនៅពេលដែលការរឹតបន្តឹងបញ្ហាកូវីដ-១៩ ត្រូវបានដកចេញ។

ការងើបឡើងវិញនៃការនាំចេញផ្នែកផលិតកម្ម និងការពង្រីកការនាំចេញទំនិញកសិកម្ម នឹងមានភាពល្អប្រសើរសម្រាប់ធនាគារ អេស៊ីលីដា ដោយសារអ្នកទទួលកម្ចីភាគច្រើនមានអាជីវកម្មទាក់ទងនឹងកសិផល។ ធនាគារនឹងអនុវត្តបានកាន់តែល្អប្រសើរនៅក្នុងឆ្នាំ២០២២ ដោយសារធនាគារបានវិនិយោគយ៉ាងច្រើនទៅលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល សាងសង់មជ្ឈមណ្ឌលទិន្នន័យដ៏ធំមួយ ដែលមានសុវត្ថិភាពខ្ពស់ដើម្បីរក្សាទុកទិន្នន័យ។ ការសាងសង់មជ្ឈមណ្ឌលការពារទិន្នន័យ Disaster Recovery Data Center នឹងជួយរក្សាទិន្នន័យនៅក្នុងបរិយាកាសដែលមានការការពារខ្ពស់។ ធនាគារមានទំនុកចិត្តចំពោះពេលអនាគត ជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងផលិតផល-សេវាកម្ម ដែលនឹងកាន់តែមានភាពល្អប្រសើរ។

## ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១- ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

ធនាគារ អេស៊ីលីដា ទទួលបានជោគជ័យនៅលើទីផ្សារដែលនាំមកនូវផលចំណេញអាស្រ័យដោយកត្តាពីរគឺ៖

- កំណើនសំពៀតឥណទាន ដោយសារតម្រូវការខ្ពស់នៅលើទីផ្សារលើផលិតផលឥណទានរបស់ធនាគារ ជាពិសេសសហគ្រាសធុនតូច និងមធ្យម។
- កំណើនប្រាក់បញ្ញើ-សន្សំ របស់ធនាគារ រួមជាមួយផលិតផល និងសេវាកម្មផ្សេងទៀត។

កត្តាទាំងពីរនេះត្រូវបានផ្សារភ្ជាប់ជាមួយនឹងការអភិវឌ្ឍឥតឈប់ឈរនៃប្រព័ន្ធឌីជីថលរបស់ធនាគារ ដែលផ្តល់ជូនអតិថិជននូវផលិតផល និងសេវាកម្មហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិត និងទាន់សម័យ។

ធនាគារ អេស៊ីលីដា ភីអិលស៊ី បាននិងកំពុងតែអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធចម្រុះឱ្យកាន់តែទូលំទូលាយសម្រាប់ជាជម្រើសដ៏សម្បូរបែបជាមួយនឹងការិយាល័យទាំង៣១៩ តាមរយៈការផ្លាស់ប្តូរបន្តិចម្តងៗទៅជាមជ្ឈមណ្ឌលដែលអាចធ្វើស្វ័យប្រតិបត្តិការដែលមានទីតាំងធនាគារស្វ័យប្រវត្តិចំនួន១១៤ ព្រមទាំងមាន **ម៉ាស៊ីនអេធីអឹមអេស៊ីលីដា** ចំនួន១.១១០គ្រឿង **ម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់** ចំនួន២៦គ្រឿង **ម៉ាស៊ីនបើកគណនីនិងបោះពុម្ពប័ណ្ណអេធីអឹម** ចំនួន២៤គ្រឿង **ម៉ាស៊ីនទទួល**

កាបូបប្រាក់ ចំនួន១២គ្រឿង និងម៉ាស៊ីនឆូតកាតចំនួន៤.២២៣គ្រឿង។ ចំណុចគួរជាទីមោទកភាពគឺធនាគារ អេស៊ីលីដា បាន បោះពុម្ពប័ណ្ណអេធីអឹមអេស៊ីលីដា ចំនួន១,៧៧លានប័ណ្ណជូនដល់អតិថិជន។ បន្ថែមលើនេះ ធនាគារបានផ្តល់ ខ្សែអាយប៊ែង ច្រើនជាង ៤ពាន់ខ្សែដល់អតិថិជន។ ទន្ទឹមនឹងនេះ អេស៊ីលីដាម៉ូបាល បានទទួលប្រជាប្រិយភាពយ៉ាងខ្លាំងដែលចំនួននៃអ្នកចុះឈ្មោះប្រើប្រាស់បានកើនដល់ ២,៧៥លាននាក់ នៅដំណាច់ខែកញ្ញា ឆ្នាំ២០២២នេះ ដែលអាចជួយឱ្យចរាចរសាច់ប្រាក់បានឆាប់រហ័សនៅក្នុងសេដ្ឋកិច្ច។

ការបង្កើនភាពងាយស្រួលដល់អតិថិជន និងពង្រឹងប្រព័ន្ធសុវត្ថិភាពអ៊ិនធើណែត គឺជាចំណុចដែលធនាគារ អេស៊ីលីដា ផ្តោតការយកចិត្តទុកដាក់បំផុត។ ដើម្បីសម្រេចនូវវឌ្ឍនភាពគោលដៅដ៏រឹងមាំទាំងនេះ ធនាគារនឹងបន្តលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមរយៈការវិនិយោគលើបច្ចេកវិទ្យាទំនើបចុងក្រោយ ពង្រឹងសមត្ថភាពធនធានមនុស្ស ព្រមទាំងពង្រីកនិងកែលម្អដំណើរការអាជីវកម្ម។ ជាយុទ្ធសាស្ត្រ ធនាគារកំពុងអភិវឌ្ឍប្រព័ន្ធទូទាត់ដែលអាចឱ្យដៃគូទាំងក្នុង និងក្រៅប្រទេសអាចភ្ជាប់ប្រព័ន្ធនេះដើម្បីបម្រើអតិថិជនទៅវិញទៅមក និងឆ្លងព្រំដែន។ ប្រព័ន្ធនេះមិនត្រឹមតែផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់អតិថិជនដ៏ឆ្លាតវៃរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដៃគូអាជីវកម្មរបស់ពួកគាត់ផងដែរ។ យើងខ្ញុំទទួលស្គាល់ថាអតិថិជន និងដៃគូអាជីវកម្មទាំងអស់គឺជាបណ្តាញតភ្ជាប់ដ៏មានសារសំខាន់សម្រាប់ពង្រីកសេវាកម្មរបស់ធនាគារ និងរីកចម្រើនជាមួយគ្នា។

អេស៊ីលីដាម៉ូបាល បានកែលម្អយ៉ាងទូលំទូលាយ និងផ្លាស់ប្តូររូបរាងថ្មី កាន់តែទំនើប ងាយស្រួល និងមានសុវត្ថិភាពខ្ពស់ ជាមួយនឹងមុខងារពិសេសៗជាច្រើន។ ឥឡូវនេះ អតិថិជនទាំងអស់អាចធ្វើប្រតិបត្តិការប្រាក់បញ្ញើ-សន្សំ (សំចៃ ចរន្ត និងមានកាលកំណត់) តាមរយៈ អេស៊ីលីដាម៉ូបាល បានភ្លាមៗ ថែមទាំងទទួលបានការប្រាក់ខ្ពស់ទៀតផង។ អេស៊ីលីដាអ៊ីសប គឺជាទម្រង់ផ្សារអនឡាញ ដែលបានបង្កើតឡើងនៅក្នុង អេស៊ីលីដាម៉ូបាល សម្រាប់សាធារណជន ទិញ-លក់ផលិតផល សេវាកម្ម និងធ្វើការទូទាត់ភ្លាមៗ។

KHQR ផ្តល់នូវភាពងាយស្រួលជាងមុនជូនដល់អ្នកប្រើប្រាស់ក្នុងការធ្វើប្រតិបត្តិការទូទាត់ថ្លៃទំនិញ និងសេវាកម្មផ្សេងៗប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព និងទំនុកចិត្តខ្ពស់ រវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដែលជាសមាជិករបស់កម្មវិធីបាគង (**Bakong App**) ។

ដើម្បីគាំទ្រដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ (ក្នុងអំឡុងពេលនៃការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩) ឱ្យមានសន្ទនីយភាពបន្ថែមទៀតដើម្បីឆ្លើយតបទៅនឹងតម្រូវការទុនរបស់ខ្លួន ធនាគារជាតិ នៃ កម្ពុជា បានបន្ធូរបន្ថយអនុបាតមួយចំនួនដូចជាៈ សាធនភាព ទ្រនាប់ដើមទុន ប្រាក់បម្រុងកាតព្វកិច្ច។ល។ ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកាត់បន្ថយពន្ធកាត់ទុកលើការប្រាក់កម្ចី ក៏ដូចជាបង្កើតសន្ទនីយភាពបន្ថែមទៀតនៅលើទីផ្សារដែលមានថ្លៃដើមទាប។ កត្តាទាំងនេះបានផ្តល់ឱកាសសម្រាប់ការប្រកួតប្រជែងថ្លៃ ដែលអាចប៉ះពាល់ដល់ចំណូលរបស់ធនាគារក្នុងរយៈពេលខ្លី ប៉ុន្តែវានឹងជួយឱ្យមានភាពរឹងមាំសម្រាប់រយៈពេលវែង។

## ២- ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ធនាគារ អេស៊ីលីដា ភីអិលស៊ី ប្រតិបត្តិការក្នុងវិស័យសេវាកម្ម ដែលការឡើងចុះនៃថ្លៃវត្ថុធាតុដើមមិនអាចអនុវត្តបានចំពោះធនាគារឡើយ។

## ៣- ការវិភាគលើពន្ធ

ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ស្ថិតនៅក្រោមច្បាប់ស្តីពីពន្ធដារនៃប្រទេសនីមួយៗ ដូច្នេះធនាគារ និងក្រុមហ៊ុន បុត្រសម្ព័ន្ធមានកាតព្វកិច្ចបង់ពន្ធតាមការកំណត់របស់អាជ្ញាធរពន្ធដារនីមួយៗ។

ការបង់ពន្ធជូនអគ្គនាយកដ្ឋានពន្ធដារមិនត្រឹមតែជាកាតព្វកិច្ច និងការទទួលបានវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទ "មាស" ពីអគ្គនាយកដ្ឋានពន្ធដារសម្រាប់ឆ្នាំជាប់ពន្ធ២០២២ ដល់២០២៣ ប៉ុណ្ណោះទេ ប៉ុន្តែជាការចូលរួមចំណែកក្នុងសង្គម និងកំណើនសេដ្ឋកិច្ចផងដែរ។

ចំណូលពន្ធគឺជាប្រភពចំណូលដ៏សំខាន់បំផុតសម្រាប់ប្រទេស។ រដ្ឋាភិបាលប្រមូលពន្ធកាន់តែច្រើន ការចូលរួមវិភាគទានកាន់តែច្រើនដល់ការអភិវឌ្ឍប្រទេស។ ធនាគារ អេស៊ីលីដា ភីអិលស៊ី ជាធនាគារដែលបានបង់ពន្ធដារច្រើនបំផុតលំដាប់ទី៥ ក្នុងចំណោមអ្នកបង់ពន្ធទាំងអស់ក្នុងឆ្នាំ២០២១។ ធនាគារ អេស៊ីលីដា ភីអិលស៊ី មានមោទកភាពដែលអាចចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាយើង។

### ៤- ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

ធនាគារមិនមានធាតុ ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលខុសពីធម្មតាជាសារវន្តនោះទេ។ ទោះជាយ៉ាងណាក៏ដោយ លក្ខខណ្ឌសេដ្ឋកិច្ចដែលបានរងផលប៉ះពាល់ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសវីរុសកូវីដ-១៩ បំប្លែងថ្មី ឆ្លងចូលក្នុងសហគមន៍ក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ២០២១ អាចជះឥទ្ធិពលដល់សមត្ថភាពសងត្រលប់មកវិញរបស់អតិថិជន ដែលគុណភាពឥណទានរបស់ធនាគារអាចរងផលប៉ះពាល់បន្តិចបន្តួច។

## គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ដើម្បីចូលរួមគាំទ្រការរីកលូតលាស់អាជីវកម្មរបស់អតិថិជន ធនាគារ អេស៊ីលីដា ភីអិលស៊ី បានបញ្ចុះអត្រាការប្រាក់លើការស្នើសុំឥណទានថ្មីគ្រប់ប្រភេទ និងដោយកាន់តែមានភាពងាយស្រួល អតិថិជនទាំងអស់អាចដាក់សំណើសុំឥណទានតាមរយៈ **អេស៊ីលីដា ម៉ូបាល**។ ជាលទ្ធផល សមតុល្យឥណទានដុលសរុបនៅត្រីមាសទី៣ ឆ្នាំ២០២២ មានការកើនឡើងចំនួន ៣,៦០ ទ្រីលានរៀល ស្មើនឹង ១៦,២៧% ធៀបនឹងដំណាច់ឆ្នាំ២០២១។

## ឃ- ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

សម្រាប់ត្រីមាសទី៣ ឆ្នាំ២០២២ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារមានការប្រែប្រួលក្នុងចន្លោះពី ៤.០៩៨-៤.១១៦ ក្នុងមួយដុល្លារអាមេរិក បានឡើងថ្លៃបន្តិចបើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន (ក្នុងចន្លោះពី ៤.១១០-៤.១២៣ ក្នុងមួយដុល្លារ)។ បើក្រឡេកមើលទៅខាងមុខ ដោយសារតែធនាគារកណ្តាលសហរដ្ឋអាមេរិកបានដំឡើងអត្រាការប្រាក់ និងការឡើងថ្លៃនៃប្រាក់ដុល្លារអាមេរិក ដែលជាហេតុបណ្តាលឱ្យអត្រាប្តូរប្រាក់ដុល្លារធៀបនឹងប្រាក់រៀលប្រែប្រួលខ្លាំងជាងពេលធម្មតា ប៉ុន្តែការប្រែប្រួលនេះនឹងស្ថិតក្នុងកម្រិតដែលអាចគ្រប់គ្រងបាន ក្រោមការឃ្លាំមើលយ៉ាងហ្មត់ចត់ពីធនាគារជាតិ នៃ កម្ពុជា។ ចំពោះធនាគារ អេស៊ីលីដា ភីអិលស៊ី បានធ្វើការវាស់វែង ត្រួតពិនិត្យ និងគ្រប់គ្រងជាប្រចាំថ្ងៃ ដើម្បីចាត់វិធានការទាន់ពេលវេលា តាមការចាំបាច់ ដោយបានរក្សាស្ថានភាពរូបិយប័ណ្ណចំហតូចល្មម អនុវត្តតាមតម្រូវការនៃបទប្បញ្ញត្តិ និងគោលនយោបាយហានិភ័យផ្ទៃក្នុងរបស់ខ្លួន។ អាស្រ័យហេតុនេះ មិនមានផលប៉ះពាល់គួរឱ្យកត់សម្គាល់ចំពោះធនាគារឡើយ។

អត្រាការប្រាក់លើទីផ្សារក្នុងស្រុកបានកើនឡើងបន្តិច ដោយសារមានការដំឡើងអត្រាការប្រាក់នៅលើទីផ្សារអន្តរជាតិ ដើម្បីឱ្យប្រាក់ដុល្លារអាមេរិកឡើងថ្លៃ (ដើម្បីទប់ទល់នឹងអត្រាអតិផរណាខ្ពស់ដែលបណ្តាលមកពីសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន) និងមួយផ្នែកទៀត មកពីការចំណាយថ្លៃដើមលើការផ្តល់ហិរញ្ញប្បទានពីក្រៅប្រទេសក៏បានកើនឡើងផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ធនាគារបានដំណើរការអាជីវកម្មរបស់ខ្លួនស្ទើរតែទាំងស្រុងដោយធ្វើការផ្គូរផ្គងរវាងទ្រព្យសកម្ម និងបំណុល លើអត្រាការប្រាក់ថេរ ដែលមានទំនាក់ទំនងដោយប្រយោល និងតិចតួចបំផុតជាមួយនឹងការប្រែប្រួលនៃអត្រាការប្រាក់នៅក្នុងទីផ្សារហិរញ្ញវត្ថុអន្តរជាតិ។ ដូច្នេះ ផលប៉ះពាល់នៃការប្រែប្រួលអត្រាការប្រាក់លើអាជីវកម្មរបស់ធនាគារមានកម្រិតតិចតួចបំផុត ហើយការប្រែប្រួលត្រូវបានត្រួតពិនិត្យជាប្រចាំ ដើម្បីចាត់វិធានការសមស្រប និងទាន់ពេលវេលា ដែលអាចជៀសវាងរាល់ផលប៉ះពាល់ទៅលើអាជីវកម្មរបស់ធនាគារ។

ដោយឡែកចំពោះប្រតិបត្តិការជួញដូរនានា ដែលមានទម្រង់ជាទំនិញ (Commodities) ធនាគារមិនមានផ្តល់សេវាបែបនោះទេ។ ដូច្នេះមិនមានផលប៉ះពាល់ដល់ធនាគារឡើយ។

## ង- ផលប៉ះពាល់នៃអតិផរណា

អតិផរណាត្រូវបានព្យាករថានឹងកើនឡើងក្នុងរង្វង់ប្រហែល ៥% ដោយសារតែការប្រែប្រួលនៃតម្លៃស្បៀងអាហារ និងប្រេង ដែលបណ្តាលមកពីសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន។ ជាទូទៅវានឹងមានផលប៉ះពាល់ខ្លះៗដល់ការចំណាយរបស់អ្នកប្រើប្រាស់ ប៉ុន្តែផលប៉ះពាល់នោះនឹងត្រូវបានប៉ះប៉ូវមកវិញ ដោយសារមានការរំពឹងទុកពីការងើបឡើងវិញនៃសេដ្ឋកិច្ច។ ទោះយ៉ាងណា ប្រតិបត្តិការរបស់ធនាគារ មិនជាប់ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងកម្រិតអតិផរណានោះទេ។ ហេតុដូច្នេះ មិនមានផលប៉ះពាល់គួរឱ្យកត់សម្គាល់ដល់ធនាគារឡើយ។

## ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល

- **គោលនយោបាយសេដ្ឋកិច្ចៈ**

ធនាគារជាតិ នៃ កម្ពុជា បានផ្តល់ជារបាយការណ៍ថា កំណើនសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០២២ នឹងសម្រេចបានក្នុងរង្វង់ ៥,៣% ដែលគាំទ្រដោយវិស័យចម្បងនានារួមមាន (១) វិស័យកាត់ដេរត្រូវបានរំពឹងថានឹងមានកំណើន ៩,៦% គាំទ្រជាចម្បងដោយភាពប្រសើរឡើងនៃតម្រូវការខាងក្រៅ គួបផ្សំនឹងវិធានការគាំទ្ររបស់រដ្ឋាភិបាល។ (២) វិស័យសំណង់រំពឹងថាមានកំណើនទាប ១,២% ដែលគាំទ្រដោយកំណើនលំហូរទុនវិនិយោគបរទេស តម្រូវការក្នុងស្រុក និងឥណទានទៅកាន់វិស័យសំណង់។ (៣) វិស័យកសិកម្មត្រូវបានព្យាករថាមានកំណើន ១,២% រួមចំណែកដោយភាពអំណោយផលនៃកត្តាអាកាសធាតុ ការចូលជាធរមានកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី។ (៤) វិស័យទេសចរណ៍ត្រូវបានរំពឹងថាមានកំណើនខ្ពស់ជាងឆ្នាំមុនដល់ ៦,១% ដោយសារការដកចេញវិធានសុខាភិបាលសម្រាប់ការធ្វើដំណើរមកកម្ពុជា និងការដាក់ចេញផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍។ (៥) វិស័យហិរញ្ញវត្ថុ ជាពិសេសវិស័យធនាគារ ចូលរួមគាំទ្រកំណើនសេដ្ឋកិច្ចតាមរយៈការផ្តល់ហិរញ្ញប្បទាននិងសេវាហិរញ្ញវត្ថុនានាដោយឥណទាន ត្រូវបានរំពឹងថានឹងមានកំណើនក្នុងអត្រា ២៣% គួបផ្សំនឹងការបន្តអនុវត្តវិធានការគាំទ្រដទៃទៀត។ ស្របគ្នានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏បានព្យាករផងដែរថា សេដ្ឋកិច្ចកម្ពុជាត្រូវរំពឹងថានឹងកើនឡើងចំនួន ៥,៤% សម្រាប់ឆ្នាំ២០២២ (ដែលធ្លាក់ចុះពី ៥,៦% កាលពីដើមឆ្នាំ) ដែលរួមចំណែកដោយ (១) តម្រូវការទីផ្សារធំៗរបស់កម្ពុជា នៅតែមានតម្រូវការ ព្រមទាំងសកម្មភាពធុរកិច្ច និងខ្សែច្រវាក់ផ្គត់ផ្គង់ផលិតកម្មក្នុងស្រុកមានភាពល្អប្រសើរ (២) រាជរដ្ឋាភិបាលបានបន្តអនុវត្តវិធានការអន្តរាគមន៍ ដូចជា ការឧបត្ថម្ភសាច់ប្រាក់ដល់ប្រជាជនងាយរងគ្រោះ និងការផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មករ-និយោជិតក្នុងអំឡុងពេលព្យួរការងារជាដើម និង (៣) ស្ថានភាពសេដ្ឋកិច្ចបាននឹងកំពុងងើបឡើង តាមរយៈការកើនឡើងនៃភ្ញៀវទេសចរអន្តរជាតិ គម្រោងវិនិយោគលើវិស័យឧស្សាហកម្ម និងការបន្តកើនឡើងនូវផលិតកម្មក្នុងស្រុក ស្របពេលដែលការនាំចេញបន្តមានកំណើនល្អ លើផលិតផលកាត់ដេរ និងផលិតផលមិនមែនកាត់ដេរ។ [(១),(២)]

យោងតាមព័ត៌មានដែលបានចុះផ្សាយនៅក្នុងអំឡុងខែកញ្ញា ស្ថាប័នល្បីល្បាញមួយចំនួននៅបន្តព្យាករផលិតផលក្នុងស្រុកសរុប (GDP) ឆ្នាំ២០២២ របស់កម្ពុជាផងដែរ។ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានរក្សាការព្យាករសេដ្ឋកិច្ចរបស់កម្ពុជាចំនួន ៥,៣% នៅឆ្នាំ២០២២ និងបានទម្លាក់ការព្យាករកាលពីដើមឆ្នាំពី ៦,៥% មក ៦,២% សម្រាប់ឆ្នាំ២០២៣ ដោយសារកំណើនខ្សោយរបស់សេដ្ឋកិច្ចសាកល។ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ក៏បានបន្ទាបការព្យាករកំណើនផលិតផលក្នុងស្រុកសរុបពិតរបស់កម្ពុជាផងដែរពី ៥,១% កាលពីខែមេសា មកនៅត្រឹម ៥% សម្រាប់ឆ្នាំ២០២២ និងបន្ទាបការប៉ាន់ស្មានលើស៦% កាលពីដើមឆ្នាំ មកនៅក្នុងរង្វង់ ៥,៥% សម្រាប់ឆ្នាំ២០២៣។ ការរំពឹងទុកនេះត្រូវបានគាំទ្រជាចម្បងដោយទំហំនាំចេញខ្លាំងកាលពីដើមឆ្នាំ គួបផ្សំដោយចេះតែបន្តនូវគោលនយោបាយគាំទ្រនិងការងើបឡើងវិញនៃវិស័យទេសចរណ៍ បើទោះបីជាបានទទួលរងសម្ពាធនានាពីខាងក្រៅ និងផលប៉ះពាល់នៃការកើនឡើងថ្លៃទៅលើចំណូលពិតក្រោយដកពន្ធក៏ដោយ។ ធនាគារពិភពលោក (WB) បានដំឡើងការព្យាករកំណើនសេដ្ឋកិច្ចរបស់កម្ពុជាសម្រាប់ឆ្នាំ២០២២ ពី ៤,៥% កាលពីខែមេសា ឡើងដល់ ៤,៨% ដោយសារកត្តាកំណើនទៅលើការនាំចេញនានារួមមាន សម្លៀកបំពាក់ ស្បែកជើង ទំនិញធ្វើដំណើរ កង់ និងសម្ភារកសិកម្ម ដែលបន្តគាំទ្រដល់ការស្តារសេដ្ឋកិច្ចឡើងវិញក្រោយបញ្ចប់កូវីដ-១៩។ ស្របគ្នានេះផងដែរ កំណើនសេដ្ឋកិច្ចរបស់កម្ពុជាក្នុងឆ្នាំ២០២៣ ត្រូវបានរំពឹងថានឹងកើនឡើងដល់ ៥,២% គាំទ្រដោយការស្ទុះងើបឡើងវិញនូវចំណាយប្រើប្រាស់របស់គ្រួសារនៅក្នុងប្រទេស ខណៈដែលអត្រាប្រកបការងារកើនឡើង រួមជាមួយនឹងចំណាយរដ្ឋាភិបាលខ្ពស់ នៅក្នុងអំឡុងពេលបោះឆ្នោត និងអតិផរណាធ្លាក់ចុះ។ [(៣),(៤),(៥),(៦)]

- **គោលនយោបាយសារពើពន្ធ៖**

សម្រាប់ឆ្នាំ២០២២ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវវិធានការសំខាន់ៗ និងជាយុទ្ធសាស្ត្រសំខាន់ៗដូចតទៅ (១) បន្តពង្រឹងការអនុវត្តវិធានការចាំបាច់នានាដូចមានកំណត់ក្នុងយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣។ (២) បន្តការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសារពើពន្ធថ្មី ដោយចាប់ផ្តើមបើកការពិភាក្សាកម្រិតក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីឲ្យការរៀបចំមានភាពគ្រប់ជ្រុងជ្រោយ និងប្រទាក់ក្រឡា ព្រមទាំងឆ្លើយតបនឹងការរីកចម្រើននៃសេដ្ឋកិច្ចជាតិ ធានាភាពច្បាស់លាស់ ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព នីត្យានុកូលភាព និងសង្គតិភាពនៃការគ្រប់គ្រងប្រមូលចំណូលពន្ធ។ (៣) រៀបចំយន្តការដើម្បីគ្រប់គ្រងចំណូលក្នុងវិស័យធំៗដែលជាសក្តានុពលសម្រាប់ចំណូលពន្ធ រួមមាន៖ (ក) បន្តពង្រឹងការអនុវត្តកាតព្វកិច្ចដំឡើងឧបករណ៍វាស់ចំណុះស្រាបៀរ និងភេសជ្ជៈគ្មានជាតិអាល់កុលរបស់សហគ្រាសផលិតក្នុងស្រុក (Flowmeter), (ខ) ពង្រឹងកិច្ចសហការជាមួយមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា (DMC), (គ) រៀបចំយន្តការកំណត់អត្តសញ្ញាណអចលនទ្រព្យ (Property ID) ដើម្បីបញ្ជាក់ថាអចលនទ្រព្យនីមួយៗបានបង់ពន្ធរួចរាល់ ចៀសវាងការលក់ដូរអចលនទ្រព្យដោយមិនបានបង់ពន្ធ, (ឃ) រៀបចំធ្វើទំនើបកម្មយន្តការត្រួតពិនិត្យតាមដានការដឹកជញ្ជូនផលិតផលតេលសិលា និងគ្រឿងសំណង់ តាមរយៈការដំឡើងឧបករណ៍តាមដាន (GPS និង RFID) តាមរថយន្តដឹកជញ្ជូននិងស្ថានីយ ដើម្បីពង្រឹងការអនុវត្តយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលដែលមានអភិបាលកិច្ចល្អជាស្នូល ការលើកកម្ពស់អនុលោមភាព និងធានាបាននូវការប្រកួតប្រជែងដោយស្មើភាព, (ង) រៀបចំយន្តការសហការជាមួយក្រុមហ៊ុនផ្គត់ផ្គង់សេវាអ៊ីនធើណែត (ISPs) ដែលកំពុងប្រតិបត្តិការក្នុងស្រុក ដើម្បីចាត់វិធានការគ្រប់គ្រងលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-commerce)។ (៤) បន្តពង្រឹងការអនុវត្តវិធានការទារបំណុលពន្ធរ៉ាំរ៉ៃ និងគោរពស្នើសុំគោលការណ៍សម្រេចទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំពោះករណីសហគ្រាសរឹងរូសពុំព្រមចូលខ្លួនមកទូទាត់បំណុលពន្ធ។ (៥) បន្តពង្រឹងការគ្រប់គ្រងប្រមូលចំណូលពន្ធលើវិស័យដែលនៅមានសក្តានុពល ដើម្បីធានាបាននូវប្រសិទ្ធភាព តម្លាភាព និងការប្រកួតប្រជែងដោយស្មើភាព។ (៦) ជំរុញសហគ្រាសក្នុងវិស័យល្បែងពាណិជ្ជកម្ម (កាស៊ីណូ) ឲ្យចូលខ្លួនមកចុះបញ្ជីពន្ធដារ និងអនុវត្តកាតព្វកិច្ចសារពើពន្ធឲ្យបានត្រឹមត្រូវ ស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ និងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម។ (៧) បន្តធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងកម្មវិធីតាមរយៈការអភិវឌ្ឍ និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធនិងកម្មវិធីថ្មីៗ។ (៨) បន្តពង្រឹងការផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ កំណែទម្រង់ និងទំនើបកម្មរដ្ឋបាលសារពើពន្ធ និងបន្តពង្រឹងការផ្តល់សេវាជូនអ្នកជាប់ពន្ធ តាមរយៈការរៀបចំកម្មវិធីរៀនអំពីពន្ធដារតាមអនឡាញ (Tax Education) កិច្ចប្រជុំ សិក្ខាសិលា វិបស្សនា គេហទំព័រ ទំព័រទំនាក់ទំនងសង្គម និងការផ្សាយផ្ទាល់តាមអនឡាញ ជាពិសេសការរៀបចំកម្មវិធី "ពន្ធដារកម្ពុជា" ដោយមានការជួបជជែកជាមួយអ្នកជាប់ពន្ធផ្ទាល់តាមប្រព័ន្ធបណ្តាញសង្គម GDT Facebook Live, សេវាឆ្លើយតបតាមប្រព័ន្ធទូរស័ព្ទ Call Center ១២៧៧, កម្មវិធី GDT Live Chat ជាដើម។ (៩) បន្តការងារកែទម្រង់ធនធានមនុស្ស និងបន្តពង្រឹងការអនុវត្តច្បាប់ វិន័យការងារ និងត្រូវមានភាពទន់ភ្លន់តែម៉ឺងម៉ាត់ ដោយផ្អែកលើទិដ្ឋភាពច្បាប់ក្នុងការផ្តល់សេវាជូនអ្នកជាប់ពន្ធ និងការគ្រប់គ្រងប្រមូលចំណូលពន្ធ។ [៧]

សរុបរយៈពេល៩ខែ ឆ្នាំ២០២២ ចំណូលពន្ធ-អាករដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានជាក់ស្តែង តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញ របស់អគ្គនាយកដ្ឋានពន្ធដារមានចំនួន ១០.៩០៨,១៩ ប៊ីលានរៀល (ប្រមាណជា ២.៦៩៣,៣៨ លានដុល្លារអាមេរិក) ស្មើនឹង ៩៥,៩៣% នៃផែនការស្តីពីច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២២ ធៀបនឹងចំណូលពន្ធ-អាករក្នុងរយៈពេលដូចគ្នាឆ្នាំ២០២១ ឃើញថាកើនឡើងចំនួន ២.៣៥១,០៧ ប៊ីលានរៀល (ប្រមាណជា ៥៨០,៥១ លានដុល្លារអាមេរិក) ឬស្មើនឹង ២៧,៥០% ។ ចំពោះលទ្ធផលប្រមូលពន្ធក្នុងខែកញ្ញា ឆ្នាំ២០២២ បានបង្ហាញថាចំណូលពន្ធ-អាករគ្រប់ប្រភេទដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានជាក់ស្តែង មានចំនួន ១.០២៨,៩៥ ប៊ីលានរៀល (ប្រមាណជា ២៥៤,០៦លានដុល្លារអាមេរិក ឬស្មើនឹង ៩,០១% នៃផែនការប្រចាំឆ្នាំ២០២២) កើនឡើងចំនួន ២១២,២១ ប៊ីលានរៀល (ប្រមាណជា ៥២,៤០ លានដុល្លារអាមេរិក ឬស្មើនឹង ២៥,៩៨%) បើប្រៀបធៀបនឹងចំណូលពន្ធ-អាករប្រចាំខែកញ្ញា ឆ្នាំ២០២១។ [៨]

- **គោលនយោបាយរូបិយវត្ថុ៖**

សម្រាប់ឆ្នាំ២០២២ ធនាគារជាតិ នៃ កម្ពុជា បានកំណត់អនុវត្តន៍គោលនយោបាយរូបិយវត្ថុចំនួន៥ ដើម្បីគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការស្តារកំណើនសេដ្ឋកិច្ចជាតិ រួមមាន៖ (១) គ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុឲ្យស្ថិតក្នុងកម្រិតសមស្រប (២) រក្សាស្ថិរភាពអត្រាប្តូរប្រាក់ ដើម្បីរួមចំណែកស្ថិរភាពថ្លៃ និងជំនឿទុកចិត្តរបស់សាធារណជន (៣) លើកកម្ពស់ការប្រើប្រាស់ប្រាក់

រៀលតាមយន្តការទីផ្សារ (៤) អភិវឌ្ឍឧបករណ៍គោលនយោបាយរូបិយវត្ថុថ្មីៗ និង (៥) ជំរុញការអភិវឌ្ឍទីផ្សារអន្តរធនាគារ ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ។ [៩]

ឯកសារយោងៈ


(១) https://www.nbc.org.kh/download_files/publication/annual_rep_kh/Semi%20Annual%20Report%202022_KHVersion.pdf

(២) https://mef.gov.kh/documents/%E1%9E%96%E1%9F%92%E1%9E%9A%E1%9E%B9%E1%9E%8F%E1%9F%92%E1%9E%8F%E1%9E%B7%E1%9E%94%E1%9E%8F%E1%9F%92%E1%9E%9A%E2%80%8B%E1%9E%9F%E1%9F%92%E1%9E%90%E1%9E%B7%E1%9E%8F%E1%9E%B7%E2%80%8B%E1%9E%9F-22/

(៣) https://www.khmertimeskh.com/501155788/adb-retains-cambodias-growth-forecast-at-5-3-percent-in-2022-and-6-2-percent-in-2023-down-by-0-3-percent/

(៤) https://www.phnompenhpost.com/business/imf-adb-peg-2022-gdp-growth-5

(៥) https://www.imf.org/en/News/Articles/2022/09/20/pr22312-cambodia-imf-staff-completes-2022-article-iv-mission-to-cambodia

(៦) https://www.phnompenhpost.com/business/wb-raises-2022-cambodia-gdp-growth-forecast-48

(៧) https://www.tax.gov.kh/u6rhf7ogbi6/gdtstream/c8e3215e-98ef-4dc0-9b95-5b1bf767741e

(៨) https://www.tax.gov.kh/u6rhf7ogbi6/gdtstream/43d42aef-792b-4ac2-9b39-396974e0e887

(៩) https://www.nbc.org.kh/download_files/publication/annual_rep_kh/Annual%20Report%202021%20Publish.pdf


**ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ**

ថ្ងៃសុក្រ ៣រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២២

បានអាន និងឯកភាព

ជ. ហត្ថលេខា

**ឆាយ សឿន**

**ប្រធានក្រុមប្រឹក្សាភិបាល**

អេស៊ីលីដា
ACLEDA BANK